ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

✿✿✿✿✿✿✿

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ១០៧៦ អយក.ប្រក

# ប្រកាស

## ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន “ **សាលាបញ្ញាសាស្ត្រអន្តរជាតិ** ” ស្ថិតនៅក្នុង សង្កាត់ បឹងកេងកង៣ ខណ្ឌ ចំការមន រាជធានីភ្នំពេញ

---

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យ លេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ មិថុនា ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន
- យោងលិខិតស្នើសុំរបស់ លោក សំ សំអាង ចុះថ្ងៃទី ២០ មេសា ២០០៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និងអភិបាល រាជធានីភ្នំពេញ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

### សម្រេច

**ប្រការ១** : អនុញ្ញាតឱ្យបើកសាលាចំណេះទូទៅឯកជន “ **សាលាបញ្ញាសាស្ត្រអន្តរជាតិ** ” ចាប់ពីកំរិតបឋមភូមិ ដល់ទុតិយភូមិ ស្ថិតនៅក្នុង សង្កាត់ បឹងកេងកង៣ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

**ប្រការ២** : សាលារៀនឯកជន **សាលាបញ្ញាសាស្ត្រអន្តរជាតិ** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ និងត្រូវ អនុវត្តកម្មវិធីសិក្សាតាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ៣** : **លោក សំ សំអាង** ជានាយកសាលាត្រូវដឹកនាំ ចាត់តាំង គ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេស ព្រមទាំងទទួលខុសត្រូវក្នុងការងារ :

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប ។
- ជ្រើសរើសសិស្សឱ្យចូលរៀន ។
- ធានាដំណើរការបង្រៀន និងរៀនឱ្យបានល្អ ។
- គោរព និងអនុវត្តសារាចរ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- ធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- រាយការណ៍រាល់សកម្មភាពសិក្សាជូនមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ តាមកាលកំណត់ ។

**ប្រការ៤** : ក្រសួងអប់រំ យុវជន និង កីឡា មានសិទ្ធិធ្វើអធិការកិច្ច ត្រួតពិនិត្យ ហើយមានសិទ្ធិបិទ ប្រសិនបើសាលារៀននេះអនុវត្តខុសពីគោលការណ៍អប់រំរបស់រដ្ឋ ។

**ប្រការ៥** : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ និងនាយកសាលារៀនសាមីមានភារកិច្ចរៀង១ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០

**<u>កន្លែងទទួល:</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
" ដើម្បីជ្រាបជាពតិមាន "
-សាលាក្រុងភ្នំពេញ "ដើម្បីជាពតិមាន"
-ដូចប្រការ៥
-កាលប្បវត្តិ-ឯកសារ នា.មចទ

**បណ្ឌិត កុល ផេង**